**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

នាយកដ្ឋានព័ត៌មាន

# សេចក្តីប្រកាសព័ត៌មាន

តាមការផ្តួចផ្តើមពីសំណាក់ភាគីបារាំង ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Jean-Yves LE DRIAN រដ្ឋមន្ត្រីក្រសួងកិច្ចការអឺរ៉ុប និងការបរទេសបារាំង នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៧ នាទីក្រុងប៉ារីស ។

នៅក្នុងជំនួបពិភាក្សានេះ ឯកឧត្តមទេសរដ្ឋមន្ត្រី និង សមភាគីបារាំង បានសំដែងនូវសេចក្តីសប្បាយរីករាយអំពីភាពវិជ្ជមាននៃកិច្ចសហប្រតិបត្តិការទូទៅរវាងប្រទេសយើងទាំងពីរ និង បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យសម្រាប់នាពេលអនាគត ជាពិសេស លើវិស័យនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ វប្បធម៌ សន្តិសុខ ។ល។

ឯកឧត្តម LE DRIAN បានសំដែងការពេញចិត្តចំពោះការចូលរួមរបស់កម្ពុជាក្នុងប្រតិបត្តិការថែរក្សាសន្តិភាពនៅក្នុងក្របខ័ណ្ឌអ.ស.ប. និង បានចូលរួមរំលែកទុក្ខជាមួយប្រជាជនកម្ពុជា ចំពោះការបាត់បង់នូវទាហានមួកខៀវកម្ពុជានៅប្រទេសអាហ្វ្រិកកណ្តាល ។

ឯកឧត្តមរដ្ឋមន្ត្រីការបរទេសបារាំង បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការយោធារវាងប្រទេសយើងទាំងពីរ ដែលក្នុងនោះ បារាំងបានចូលរួមចំណែកបណ្តុះបណ្តាលកងកម្លាំងមួកខៀវកម្ពុជា និងអះអាងថានឹងបន្តគាំទ្រកិច្ចខិតខំប្រឹងប្រែងនេះ ដែលចូលរួមចំណែកដល់ការលើកតម្កើង ហ្វ្រង់កូហ្វូនីកងទ័ព ( Francophonie armée ) ។

នៅក្នុងវិស័យបេតិកភណ្ឌ ឯកឧត្តម បានគូសបញ្ជាក់អំពីលទ្ធផលវិជ្ជមានដ៏ខ្លាំងក្លានៃការងាររបស់បារាំងក្នុងនាមជាសហប្រធាន ICC Angkor ។

ជាមួយគ្នានេះ ឯកឧត្តមរដ្ឋមន្ត្រី បានលើកឡើងពីលទ្ធលវិជ្ជមាននៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច (ការផ្លាស់ប្តូរសេដ្ឋកិច្ច សកម្មភាពរបស់ AFD ...) ដែលចូលរួមចំណែកដល់ការធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាមានសភាពរឹងមាំ ។

ជាកិច្ចឆ្លើយតប ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះការចូលរួមរំលែកទុក្ខរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេសបារាំង និងចំពោះការចូលរួមចំណែករបស់បារាំង



អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ក្នុងការបណ្តុះបណ្តាលកងកម្លាំងមួកខៀវកម្ពុជា ។ កម្ពុជា ដែលពីមុន ធ្លាប់ទទួលកងទ័ពមួកខៀវនៅដើមទសវត្ស១៩៩០ បានចាប់ផ្តើមបញ្ជូនកងទ័ពមួកខៀវដំបូងទៅបរទេសក្រោមឆ័ត្រអ.ស.ប. នៅឆ្នាំ២០០៦ ទៅប្រទេសស៊ូដង់ ហើយជាបន្តបន្ទាប់មក ទៅប្រទេសនិយាយភាសាបារាំង តាមការអំពាវនាវរបស់អតីតអគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) ។ ចំពោះ អង្គការអន្តរជាតិហ្វ្រង់កូហ្វូនី កម្ពុជាជាសមាជិកមួយ ដែលមានតំណាងចូលរួមយ៉ាងសកម្មនៅគ្រប់ស្ថាប័នតំណាងទាំងអស់របស់អង្គការ OIF (ថ្នាក់តំណាងអចិន្ត្រៃយ៍ ថ្នាក់រដ្ឋមន្ត្រី និង ថ្នាក់ដឹកនាំកំពូល) និង បានបង់វិភាគទានទៀងទាត់។

ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានស្នើសុំឱ្យបារាំងពិចារណាអំពីការពង្រីកសមត្ថកិច្ចរបស់ ICC Angkor ដល់តំបន់ប្រាសាទសំបូរព្រៃគុក ហើយនិងជួយដល់វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដែលទើបតែបង្កើតថ្មីៗនេះនៅក្រោមសមត្ថកិច្ចក្រសួងការបរទេស ជាពិសេស ដល់ការដាក់ឱ្យដំណើរការ តាមរយៈការចុះកិច្ចព្រមព្រៀងមួយ នៅពេលខាងមុខ ជាមួយស្ថាប័នសិក្សាការទូតរបស់ក្រសួងការបរទេសបារាំង។ ឯកឧត្តមរដ្ឋមន្ត្រី LE DRIAN បានទទួលយកនិងគាំទ្រសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈស្តីពីស្ថានការណ៍នយោបាយនៅកម្ពុជារយៈពេលចុងក្រោយនេះ ហើយឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានអះអាងជូនភាគីបារាំងពីការប្តេជ្ញារបស់កម្ពុជា ក្នុងការរៀបចំការបោះឆ្នោតឆ្នាំក្រោយឲ្យបានល្អ ដូចការបោះឆ្នោតឆ្នាំនេះដែរ។

នៅចុងបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី និង សមភាគីបារាំង បានយល់ស្របគ្នាលើការរៀបចំឯកសារតម្រង់ទិសថ្មីសម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ ឆ្នាំ២០១៩-២០២២ និង អនុសញ្ញាថ្មីស្តីពីកិច្ចសហប្រតិបត្តិការយោធាឆ្នាំ២០១៨-២០២០ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧